សហព័ន្ធខ្មែរកម្ពុជាក្រោម
KHMERS KAMPUCHEA-KROM FEDERATION
Asia – Australia – Europe – North America.
A member of UNPO & IDBF

**Office of President:** 190 McNay Street • London • ON • N5Y-1L3 • CANADA. Tel: (519) 659-3920, Cell (856)655-2117
http://www.khmerkrom.net • Email: thach.thach@khmerkrom.org

# សួស្តីឆ្នាំថ្មី !
# ឆ្នាំមមែ សប្តស័ក ព.ស. ២៥៥៩

សូមគោរពមកជនរួមឈាមទាំងនៅក្នុងស្រុក និងក្រៅស្រុកដោយសេចក្តីនឹករឭកអំពីយើងខ្ញុំ ព្រះករុណាខ្ញុំបាទ ។

នាឱកាសចូលឆ្នាំថ្មី ឆ្នាំមមែ សប្តស័ក ព. ស. ២៥៥៩ នេះ ក្នុងនាមសហព័ន្ធខ្មែរកម្ពុជាក្រោម សូមប្រគេន និងជូនពរដល់ជនរួមឈាមឲ្យបានប្រកបដោយសេចក្តីសុខ សុភមង្គល និងជួបជុំកូនចៅញាតិផៅសន្តាន រាល់ទិវារាត្រី ។

យើងខ្ញុំព្រះកុណាខ្ញុំបាទសូមប្រគេននិងជំរាបនូវផែនការឆ្នាំថ្មីនេះផងដែរក្រោមការសម្រេច នៃអង្គសន្និបាតប្រចាំឆ្នាំ នាទីក្រុងឡងប៊ិច រដ្ឋ កាលីហ្វញ៉ា សហរដ្ឋអាមេរិកដូច ខាងក្រោម៖

**១. កិច្ចការអន្តរជាតិ**

**២. កិច្ចការកម្ពុជាក្រោម**

**៣. កិច្ចការនៅកម្ពុជា និងប្រទេសថៃដែលមានខ្មែរក្រោមរស់នៅ**

**៤. សៀវភៅកិច្ចការរដ្ឋបាលនិងបោះពុម្ពជាថ្មីជាភាសាខ្មែរនិងអង់គ្លេស ។**

"ទោះបីជាយើងមិនអាចវិលត្រឡប់ទៅអតីតកាលវិញ និងមិនអាចចាប់ផ្តើមសាជាថ្មីយ៉ាងណាក៏ដោយ ប៉ុន្តែយើងអាចផ្តើមពន្លកថ្មី ដើម្បីសិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯង ជូនជនរួមឈាមរបស់យើងដែលជាអ្នករស់នៅក្នុងស្រុក នាពេលបច្ចុប្បន្ន បានដែរ" ។

សំឡេងតែមួយ ភាសាតែមួយ ទឹកចិត្តតែមួយ ដើម្បីខ្មែរក្រោមទាំងអស់គ្នានោះ យើងអាចនឹងទទួលបាននូវលទ្ធផលដ៏ប្រសើរ និងបានសម្រេចដូចបំណងរបស់យើងដែលបានប៉ងទុកជាយូរមកហើយនូវ "**សិទ្ធិសម្រេចវាសនាខ្លួនដោយឯង**" លើមាតុភូមិកម្ពុជាក្រោម ដ៏កម្សត់របស់យើង ។

សូមទេវតាឆ្នាំថ្មី ព្រះនាង រាក្សសៈទេវី ប្រសិទ្ធិពរបវរសួស្តី និងសូមប្រកបដោយ អាយុ វណ្ណៈ សុខៈ និង ពលៈ កុំបីឃ្លៀង ឃ្លាតឡើយ ។

សូមអរព្រះគុណនិងសូមអរគុណ

កាណាដា ថ្ងៃទី ៤ ខែមេនា ឆ្នាំ ២០១៥

**ថាច់ ឌុំក ថាច់**
ប្រធានប្រតិបត្តិនៃសហព័ន្ធខ្មែរកម្ពុជាក្រោម